# ស្ថានភាពអតិផរណានៅខែមករា ឆ្នាំ២០១៦

*******

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពពីវិទ្យាស្ថានជាតិស្ថិតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមករា ឆ្នាំ២០១៦ បានថយចុះ ០,២% ធៀបនឹងខែកន្លងទៅ ឬ បានកើនឡើង ៣% ធៀបនឹង១២ខែមុន។ បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃទំនិញភាគច្រើនមានការកើនឡើង ជាពិសេសសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងបានកើនឡើង ៤,៩% ក្នុងនោះថ្លៃត្រីស្រស់កើនឡើង ១០,៣% ថ្លៃសាច់ជ្រូកកើនឡើង ៤% ថ្លៃសាច់គោកើនឡើង ៨,៧% ថ្លៃសាច់មាន់កើនឡើង ៣,២% ថ្លៃបន្លែកើនឡើងជាង ២,៤%, សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ បានកើនឡើង ១១,៥% និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន បានកើនឡើង ៦,៨%។

ប៉ុន្តែ ក៏មានសន្ទស្សន៍ថ្លៃទំនិញខ្លះធ្លាក់ចុះដែរ ដូចជា សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត បានថយចុះចំនួន ១,១% ក្នុងនោះ ថ្លៃឧស្ម័នបានថយចុះ ១២% និងឥន្ធនៈរាវបានថយចុះ ០,៦%, សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានថយចុះចំនួន ៥,១% ក្នុងនោះ ថ្លៃប្រេងឥន្ធនៈនិងខ្លាញ់បានថយចុះ ១០,៣% ថ្លៃប្រេងសាំងបានថយចុះ ១០,៥% ប្រេងម៉ាស៊ូតបានថយចុះ ៩,៩% និងសេវាកម្មដឹកជញ្ជូន បានថយចុះ ១៧,៥%។

ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង ១២ ក្រុម មានដូចខាងក្រោម÷

| | ធៀបខែមុន | ធៀប ១២ខែមុន |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **-0.2** | **3.0** |
| ១-អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | -0.3 | 4.9 |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | 1.4 | 11.5 |
| ៣-សម្លៀកបំពាក់និងស្បែកជើង | 0.8 | 5.9 |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 0.9 | -1.1 |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -0.3 | 1.8 |
| ៦-សុខាភិបាល | -0.2 | 1.6 |
| ៧-ការដឹកជញ្ជូន | -2.5 | -5.1 |
| ៨-គមនាគមន៍ | 0.0 | 1.0 |
| ៩-ការកំសាន្ត និងវប្បធម៌ | -0.5 | 3.9 |
| ១០-ការសិក្សា | 0.0 | 0.6 |
| ១១-ភោជនីយដ្ឋាន | 0.0 | 6.8 |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -0.4 | -1.0 |

**តារាង÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារ មួយចំនួនប្រចាំឆ្នាំ២០១៥-២០១៦ (%)**

| មុខទំនិញ | ២០១៥ | ២០១៦ |
|---|---|---|
| | មករា | មករា |
| អង្ករ | 0.8 | 2.8 |
| សាច់គោ | 3.4 | 8.7 |
| សាច់មាន់ | 2.0 | 3.2 |
| សាច់ទា | 3.5 | 3.2 |
| សាច់ជ្រូក | 7.4 | 4.0 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | 4.8 | 9.8 |
| ក្នុងនោះត្រីស្រស់ | 5.6 | 10.3 |
| ផ្លែឈើ | 4.1 | 5.5 |
| ផ្លែឈើស្រស់ | 5.2 | 6.0 |
| បន្លែ | 5.3 | 2.4 |
| បន្លែជាស្លឹក | 5.2 | -0.7 |
| បន្លែជាផ្លែ | 8.5 | 2.5 |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

តារាងឧបសម្ព័ន្ធ៣÷ អតិផរណាប្រចាំឆ្នាំ (%)

| ប្រទេស | ២០១៥ | ២០១៦ |
|---|---|---|
| | មករា | មករា |
| ប្រទេសកម្ពុជា | 0.4 | 3.0 |
| ប្រទេសវៀតណាម | 0.9 | -36.7 |
| ប្រទេសថៃ | -0.41 | -0.53 |
| ប្រទេសម៉ាឡេស៊ី | 1 | 3.53 |
| ប្រទេសឥណ្ឌូនេស៊ី | 6.96 | 4.14 |
| ប្រទេសភីលីពីន | 2.40 | 1.35 |
| ប្រទេសចិន | -1.66 | 0.99 |
| ប្រទេសកូរ៉េខាងត្បូង | 0.83 | 0.79 |
| ប្រទេសជប៉ុន | 2.38 | -0.10 |

**កំណត់សម្គាល់៖** ប្រភពទិន្នន័យ(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

រៀបចំ និង ធ្វើចំណោលដោយ

នាយដ្ឋានស្ថិតិ

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ